# ប្រកាស
## ស្តីពី
## នីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសហភាពសហគមន៍កសិកម្ម

-----๛๛๛✷๛๛๛-----

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនប្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ២២០ ប្រក.កសក.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត
- បានឃើញប្រកាសលេខ០៩០ ប្រក.កសក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានឃើញប្រកាសលេខ១៨៤ ប្រក.កសក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានីខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើនិងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានីខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីសម្រាប់បង្កើតនិងចុះបញ្ជីសហភាពសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅផ្តល់គោលការណ៍ណែនាំស្តីពីនីតិវិធីបង្កើតនិងចុះបញ្ជីសហភាពសហគមន៍កសិកម្មដល់សហគមន៍កសិកម្មឬនីតិបុគ្គលឯកជនដែលមានមុខរបរក្នុងក្របខ័ណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម និងសេវាកម្មដែលពាក់ព័ន្ធផលិតកម្មកសិកម្ម ដើម្បីបង្កើតនិងចុះបញ្ជីសហភាពសហគមន៍កសិកម្ម ដោយស្របតាមច្បាប់ស្តីពីសហគមន៍កសិកម្ម។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់សហភាពសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## នីតិវិធីនៃការបង្កើតសហភាពសហគមន៍កសិកម្ម
## ផ្នែកទី១
## លក្ខខណ្ឌនៃការបង្កើតសហភាពសហគមន៍កសិកម្ម

**ប្រការ ៤.-**

សហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីចំនួន២(ពីរ)ឡើងទៅ ដែលមានសកម្មភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ឬមានទំនាក់ទំនងសេដ្ឋកិច្ចស្ថិតនៅក្នុងប្រព័ន្ធប្រតិបត្តិការមុខរបររួមគ្នា អាចរួមគ្នាបង្កើតជា"សហភាពសហគមន៍កសិកម្ម" ក្នុងគោលបំណងប្រមូលផ្តុំកម្លាំងផលិតកម្ម មធ្យោបាយផលិតកម្ម និងពង្រីកសមត្ថភាពសេដ្ឋកិច្ចនៅក្នុងក្របខ័ណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម។

**ប្រការ ៥.-**

នីតិបុគ្គលឯកជនក្រៅពីសហគមន៍កសិកម្ម ដែលមានមុខរបរចម្បងស្ថិតនៅក្នុងក្របខ័ណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម ហើយមានទំនាក់ទំនងប្រតិបត្តិការសេដ្ឋកិច្ចជាមួយសហគមន៍កសិកម្មចំនួន២(ពីរ)ឡើងទៅ ឬមានទំនាក់ទំនងប្រតិបត្តិការសេដ្ឋកិច្ចប្រហាក់ប្រហែលជាមួយសហភាពសហគមន៍កសិកម្មណាមួយអាចចូលរួមគ្នាបង្កើតជាសហភាពសហគមន៍កសិកម្មឬដាក់ពាក្យស្នើសុំចូលជាសមាជិកភាពសហភាពសហគមន៍កសិកម្មណាមួយបានដោយស្ម័គ្រចិត្ត។

**ប្រការ ៦.-**

សហភាពសហគមន៍កសិកម្មអាចបង្កើតឡើងដោយមិនអាស្រ័យដែនភូមិសាស្ត្ររដ្ឋបាលរបស់សហគមន៍កសិកម្មឬមូលដ្ឋានផលិតកម្មរបស់នីតិបុគ្គលឯកជនជាសមាជិកតាំងនៅឡើយ។ សហភាពសហគមន៍កសិកម្មអាចបង្កើតឡើងអាស្រ័យតាមសកម្មភាពសេដ្ឋកិច្ចដែលសហភាពសហគមន៍កសិកម្មនោះធ្វើប្រតិបត្តិការនៅក្នុងបីកម្រិតផ្សេងគ្នាដូចខាងក្រោម៖

១-សហភាពសហគមន៍កសិកម្មកម្រិតជាតិ គឺជាសហភាពសហគមន៍កសិកម្មដែលត្រូវបានកំណត់ឱ្យមានតែមួយនៅថ្នាក់ជាតិទៅតាមប្រភេទមុខរបរនីមួយៗមានដូចជា មុខរបរឥណទានកសិកម្ម មុខបរផ្គត់ផ្គង់ធាតុចូលកសិកម្ម មុខរបរកែច្នៃផលិតផលកសិកម្ម មុខរបរដឹកជញ្ជូនផលិតផលកសិកម្ម មុខរបរទីផ្សារផលិតផលកសិកម្ម និងមុខរបរដ៏ទៃផ្សេងទៀតដូចមានចែងនៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្មហើយដែលមុខរបរនោះមានវិសាលភាពគ្របដណ្តប់គ្រប់តំបន់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

២-សហភាពសហគមន៍កសិកម្មកម្រិតភូមិភាគ គឺជាសហភាពសហគមន៍កសិកម្មដែលមានប្រភេទមុខរបរសំខាន់យ៉ាងតិចចំនួនមួយដូចមានចែងក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម ហើយដែលមុខរបរនោះមានវិសាលភាពគ្របដណ្តប់តែលើបណ្តារាជធានីខេត្តណាដែលសហគមន៍កសិកម្មជាសមាជិកនៃសហភាពសហគមន៍កសិកម្មនោះតាំងនៅប៉ុណ្ណោះ ដោយមិនគ្របដណ្តប់លើទូទាំងប្រទេសឡើយ។

៣-សហភាពសហគមន៍កសិកម្មកម្រិតមូលដ្ឋាន គឺជាសហភាពសហគមន៍កសិកម្មដែលមានប្រភេទមុខរបរសំខាន់យ៉ាងតិចចំនួនមួយដូចមានចែងក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម ហើយដែលមុខរបរនោះមានវិសាលភាពគ្របដណ្តប់លើរាជធានីខេត្តណាមួយ ដែលសហភាពសហគមន៍កសិកម្មនោះតាំងនៅ។

**ប្រការ ៧.-**

សហគមន៍កសិកម្មឬនីតិបុគ្គលឯកជនទាំងឡាយដែលមានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធវិស័យកសិកម្មមានបំណងរួមគ្នាបង្កើតសហភាពសហគមន៍កសិកម្មឬមានបំណងចូលជាសមាជិករបស់សហភាពសហគមន៍កសិកម្ម ត្រូវមានលក្ខណៈសម្បត្តិ និងទទួលខុសត្រូវដូចខាងក្រោម៖

១- ត្រូវមាននីត្យានុកូលភាពតាមរយៈការចុះបញ្ជីសហគមន៍កសិកម្ម ឬជានីតិបុគ្គលឯកជនដែលបានចុះបញ្ជីពាណិជ្ជកម្មក្នុងរយៈពេលយ៉ាងតិច២(ពីរ)ឆ្នាំកន្លងមក ស្របតាមច្បាប់ស្តីពីសហគមន៍កសិកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មជាធរមាន។

២- ត្រូវដាក់ពាក្យស្នើសុំចូលរួមជាសមាជិកសហភាពសហគមន៍កសិកម្មដោយស្ម័គ្រចិត្ត ដោយផ្អែកតាមសេចក្តីអនុម័តយល់ព្រមឬសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតរបស់សហគមន៍កសិកម្មសាមីដែលស្នើសុំចំនួន២/៣(ពីរភាគបី)នៃសមាជិកដែលមានវត្តមាន។

៣- នីតិបុគ្គលឯកជនត្រូវដាក់ពាក្យស្នើសុំចូលរួមជាសមាជិកសហភាពសហគមន៍កសិកម្មដោយស្ម័គ្រចិត្ត ដោយផ្អែកតាមសេចក្តីសម្រេចពីប្រធានក្រុមប្រឹក្សាភិបាល ឬពីអភិបាលនៃនីតិបុគ្គលឯកជនសាមីនោះ។

៤- សហគមន៍កសិកម្ម និងនីតិបុគ្គលឯកជនដែលស្នើសុំបង្កើតសហភាពសហគមន៍កសិកម្មត្រូវសម្រេចដោយមហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម។

៥- ត្រូវសិក្សានិងស្វែងយល់អំពីបេសកកម្ម តួនាទីនិងភារកិច្ចរបស់សហភាពសហគមន៍កសិកម្ម និងផលប្រយោជន៍ដែលទទួលបានពីប្រតិបត្តិការមុខរបររួមគ្នារបស់សហភាពសហគមន៍កសិកម្ម។

៦- ត្រូវចូលរួមគាំទ្រដំណើរការអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការប្រតិបត្តិការមុខរបររបស់សហភាពសហគមន៍កសិកម្ម ព្រមទាំងដំណើរការជ្រើសតាំងក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យរបស់សហភាពសហគមន៍កសិកម្ម នៅក្នុងមហាសន្និបាតកំណើតដំបូង។

៧- ត្រូវបំពេញរាល់ភារកិច្ចនៅក្នុងដំណើរការបង្កើតសហភាពសហគមន៍កសិកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងនីតិវិធីនៃប្រកាសនេះ។

**ប្រការ ៨.-**

សហគមន៍កសិកម្មថ្មី ឬនីតិបុគ្គលឯកជនថ្មីណាមួយដែលស្នើសុំចូលជាសមាជិកភាពសហភាពសហគមន៍កសិកម្ម ត្រូវសម្រេចដោយមហាសន្និបាតសហភាពសហគមន៍កសិកម្មតាមសម្លេង ២/៣ (ពីរភាគបី) នៃប្រតិភូតំណាងដែលមានក្នុងអង្គមហាសន្និបាត។

**ប្រការ ៩.-**

ក្រោយពេលអនុម័តយល់ព្រមចូលរួមបង្កើតសហភាពសហគមន៍កសិកម្មរួចមក មហាសន្និបាតសហគមន៍កសិកម្មសាមី ត្រូវជ្រើសតាំងប្រតិភូតំណាងសហគមន៍កសិកម្មរបស់ខ្លួនសម្រាប់ចូលរួមមហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម។

ចំនួនប្រតិភូតំណាងរបស់សហគមន៍កសិកម្មនីមួយៗឬនីតិបុគ្គលឯកជនសម្រាប់ចូលរួមមហាសន្និបាតកំណើតដំបូងសហភាពសហគមន៍កសិកម្ម ត្រូវកំណត់ចំនួនស្មើគ្នា។

ចំនួនជាក់លាក់នៃប្រតិភូតំណាងត្រូវសម្រេចដោយគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម។

**ប្រការ ១០.-**

ចំនួនបេក្ខជនឈរឈ្មោះជាក់លាក់សម្រាប់សមាសភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យត្រូវកំណត់ដោយគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម។

សហគមន៍កសិកម្មនីមួយៗ មានសិទ្ធិចាត់ចំនួនបេក្ខជនឱ្យឈរឈ្មោះដោយសមាមាត្រទៅនឹងចំនួនសមាជិកសរុបរបស់សហគមន៍កសិកម្មនីមួយៗ សម្រាប់បោះឆ្នោតធ្វើជាបេក្ខភាពក្រុមប្រឹក្សាភិបាល និងបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យ។

នីតិបុគ្គលឯកជនមានសិទ្ធិចាត់បញ្ជូនបេក្ខជនដើម្បីឈរឈ្មោះសម្រាប់ធ្វើជាបេក្ខភាពក្រុមប្រឹក្សាភិបាល ឬបេក្ខភាពគណៈកម្មាធិការត្រួតពិនិត្យ។

**ប្រការ ១១.-**

នៅពេលបោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការត្រួតពិនិត្យ ក្នុងករណីមានសមាសភាពទទួលបានសម្លេងគាំទ្រស្មើគ្នា គណៈកម្មការរៀបចំត្រូវបន្តនីតិវិធីបោះឆ្នោតលើកទី២ ដើម្បីជ្រើសរើសបំពេញបង្គ្រប់សមាសភាពនៅក្នុងចំណោមបេក្ខជនដែលទទួលបានសម្លេងគាំទ្រស្មើគ្នា។

ក្នុងករណីការបោះឆ្នោតលើកទី២នៅតែមិនអាចជ្រើសរើសបាន គណៈកម្មការរៀបចំមានសិទ្ធិសម្រេចយកបេក្ខជនចុងក្រោយរបស់សហគមន៍កសិកម្មណាមួយដែលមានចំនួនភាគហ៊ុនច្រើនជាងគេនៅក្នុងសហភាពសហគមន៍កសិកម្ម។ ប៉ុន្តែក្នុងករណីនៅតែមិនអាចជ្រើសរើសបេក្ខជនចុងក្រោយបាន គណៈកម្មការរៀបចំត្រូវសម្រេចជ្រើសរើសបេក្ខជនចុងក្រោយដោយត្រូវផ្អែកតាមកម្រិតវប្បធម៌ សមត្ថភាព និងបទពិសោធន៍ការងារសហគមន៍កសិកម្ម។

## ផ្នែកទី២
## ការផ្សព្វផ្សាយគោលគំនិតសហភាពសហគមន៍កសិកម្មនិងការអង្កេតទស្សនៈ

**ប្រការ ១២.-**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត ឬ/និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានភារកិច្ចផ្សព្វផ្សាយគោលគំនិតស្តីពីសហភាពសហគមន៍កសិកម្មដល់សហគមន៍កសិកម្ម ឬនីតិបុគ្គលឯកជនដើម្បីអង្កេតទស្សនៈអំពីលទ្ធភាពនៃការចូលរួមបង្កើតសហភាពសហគមន៍កសិកម្ម។

គោលគំនិតសំខាន់ៗរបស់សហភាពសហគមន៍កសិកម្ម មានដូចខាងក្រោម៖

- និយមន័យនៃសហភាពសហគមន៍កសិកម្ម
- គោលបំណងរបស់សហភាពសហគមន៍កសិកម្ម
- គោលការណ៍គ្រឹះនិងតម្លៃរបស់សហភាពសហគមន៍កសិកម្ម
- បេសកកម្ម និងភារកិច្ចរបស់សហភាពសហគមន៍កសិកម្ម
- ផលប្រយោជន៍ដែលសមាជិកអាចទទួលបានពីសហភាពសហគមន៍កសិកម្ម
- រចនាសម្ព័ន្ធដឹកនាំរបស់សហភាពសហគមន៍កសិកម្ម
- សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកសហភាពសហគមន៍កសិកម្ម
- មុខរបរអាជីវកម្មដែលសហភាពសហគមន៍កសិកម្មអាចប្រកបដែលបានកំណត់នៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម
- លក្ខខណ្ឌនៃការបង្កើតសហភាពសហគមន៍កសិកម្ម ។

## ផ្នែកទី៣
## ការបង្កើតគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម

**ប្រការ ១៣.-**

សហគមន៍កសិកម្ម ឬនីតិបុគ្គលឯកជន ដែលមានមុខរបរក្នុងក្របខ័ណ្ឌផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មទាំងឡាយដែលពាក់ព័ន្ធផលិតកម្មកសិកម្ម មានបំណងចង់បង្កើតសហភាពសហគមន៍កសិកម្ម មានសិទ្ធិស្នើសុំទៅកាន់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដែលខ្លួនតាំងនៅ ឬអាចស្នើសុំនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយផ្សេងៗទៀត។

ក្នុងករណីសហគមន៍កសិកម្មស្នើសុំទៅកាន់អាជ្ញាធរមូលដ្ឋានសាមី ឬអ្នកពាក់ព័ន្ធផ្សេងទៀត អាជ្ញាធរមូលដ្ឋាន ឬអ្នកពាក់ព័ន្ធនោះ ត្រូវបញ្ជូនសំណើទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត សាមី ដើម្បីពិនិត្យតាមនីតិវិធី។

**ប្រការ ១៤.-**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ឬ/និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានភារកិច្ចសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបង្កើតគណៈកម្មការរៀប

ចំបង្កើតសហភាពសហគមន៍កសិកម្ម សម្រាប់ដំណើរការបង្កើតសហភាពសហគមន៍កសិកម្មដែលស្នើសុំ។

សមាសភាពគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម ត្រូវមានចំនួនយ៉ាងតិចបំផុតចាប់ពី៣ (បី)រូបឡើងទៅ។

តំណាងសហគមន៍កសិកម្មនីមួយៗ ឬនីតិបុគ្គលឯកជនដែលត្រូវចូលរួមជាសមាសភាពគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម ត្រូវមានលិខិតបញ្ជាក់ការចាត់តាំងដោយប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មសាមី ឬប្រធានក្រុមប្រឹក្សាភិបាលឬអភិបាលរបស់នីតិបុគ្គលឯកជនសាមី។

គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម មានសិទ្ធិស្នើសុំជំនួយការដើម្បីជួយដល់គណៈកម្មការ។

## ប្រការ ១៥.-

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត ឬ/និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មមានភារកិច្ចជួយគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មក្នុងការផ្សព្វផ្សាយនិងពន្យល់លក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូរបស់សហភាពសហគមន៍កសិកម្ម ដល់សហគមន៍កសិកម្មដែលស្នើសុំបង្កើតសហភាពសហគមន៍កសិកម្មដើម្បីរៀបចំបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហភាពសហគមន៍កសិកម្មសាមី។

## ប្រការ ១៦.-

គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម ត្រូវបំពេញតួនាទីរបស់ខ្លួនចាប់ពីដំណាក់កាលចាប់ផ្ដើមការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម រហូតដល់សហភាពសហគមន៍កសិកម្មត្រូវបានចុះបញ្ជីជាផ្លូវការ។

គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មត្រូវសម្របសម្រួល និងសិក្សារៀបចំឯកសារសំខាន់ៗដូចខាងក្រោម៖

- កោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម
- បូកសរុបពាក្យស្នើសុំ និងចុះឈ្មោះសហគមន៍កសិកម្មឬនីតិបុគ្គលឯកជនដែលស្ម័គ្រចិត្តចូលរួមបង្កើតសហភាពសហគមន៍កសិកម្ម
- រៀបចំបញ្ជីប្រតិភូតំណាងសហគមន៍កសិកម្ម និងនីតិបុគ្គលឯកជនដែលត្រូវចូលរួមមហាសន្និបាតតំណាងកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម
- រៀបចំរចនាសម្ព័ន្ធឈ្មោះ ស្លាកសញ្ញា និងអាសយដ្ឋានរបស់សហភាពសហគមន៍កសិកម្ម
- រៀបចំបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យក្នុងនោះបេក្ខនារីត្រូវបានលើកទឹកចិត្តនិងផ្តល់អាទិភាព
- រៀបចំសេចក្តីព្រាងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហភាពសហគមន៍កសិកម្ម
- រៀបចំផែនការមុខជំនួញរបស់សហភាពសហគមន៍កសិកម្ម

- រៀបចំឯកសារផ្សេងៗទៀតដែលជាតម្រូវការរបស់គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម។

## ផ្នែកទី៤
## ការរៀបចំមហាសន្និបាតកំណើតដំបូង

### ប្រការ ១៧.-

មហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម ត្រូវប្រព្រឹត្តទៅក្រោមរូបភាពមហាសន្និបាតតំណាង ដែលមានការចូលរួមរបស់ប្រតិភូតំណាងសហគមន៍កសិកម្ម ឬនីតិបុគ្គលឯកជនដែលស្នើសុំចូលរួមបង្កើតសហភាពសហគមន៍កសិកម្ម។

ប្រតិភូតំណាងសហគមន៍កសិកម្មសាមី ឬនីតិបុគ្គលឯកជន ដែលត្រូវចូលរួមមហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម មានសិទ្ធិបញ្ចេញមតិយោបល់នៅក្នុងមហាសន្និបាត ប៉ុន្តែត្រូវមានសម្លេងឆ្នោតឯកច្ឆ័ន្ទតែ១(មួយ)គត់តំណាងឱ្យសហគមន៍កសិកម្ម ឬនីតិបុគ្គលឯកជនសាមី ដោយអនុលោមតាមគោលការណ៍គ្រឹះរបស់សហគមន៍កសិកម្ម ដែលមានចែងនៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម។

គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មមានសិទ្ធិអញ្ជើញតំណាងអាជ្ញាធរ ផ្នែកឯកជន អង្គការសង្គម និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងមហាសន្និបាតតំណាងកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម ប៉ុន្តែអ្នកសង្កេតការណ៍ទាំងនោះពុំមានសិទ្ធិបោះឆ្នោតឡើយ។

### ប្រការ ១៨.-

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត ឬ/និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានភារកិច្ចជួយសម្របសម្រួលដល់គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មនៅក្នុងមហាសន្និបាតកំណើតដំបូង។

គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ប្រកាសអំពីសមាសភាព តួនាទីនិងភារកិច្ចរបស់គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មនៅក្នុងដំណើរការបង្កើតសហភាពសហគមន៍កសិកម្ម។
- ប្រកាសអំពីវត្តមាននៃប្រតិភូតំណាងរបស់សហគមន៍កសិកម្មនិងនីតិបុគ្គលឯកជនដែលមានចំនួនជាក់ស្តែងនៅក្នុងមហាសន្និបាតកំណើតដំបូង។
- ប្រកាសអំពីបណ្តាឯកសារដែលបានរៀបចំសម្រាប់ការបង្កើតសហភាពសហគមន៍កសិកម្ម ដូចមានចែងនៅក្នុងប្រការ១៦ខាងលើ។
- សម្របសម្រួលដំណើរការបោះឆ្នោត ដើម្បីអនុម័តយល់ព្រមលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង សមាសភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យរបស់សហភាពសហគមន៍កសិកម្ម តម្លៃភាគហ៊ុនព្រមទាំងអនុម័តលើការងារពាក់ព័ន្ធផ្សេងៗទៀត។

- ធ្វើការកត់ត្រានូវដំណើរការនិងលទ្ធផលនៃមហាសន្និបាតកំណើតដំបូង រៀបចំជារបាយការណ៍មហាសន្និបាតកំណើតដំបូង ដោយភ្ជាប់ជាមួយនូវបញ្ជីវត្តមានរួមជាមួយហត្ថលេខាឬស្នាមមេដៃរបស់សមាជិកដែលបានចូលរួមក្នុងមហាសន្និបាត។

## ជំពូកទី៣
## ការរៀបចំឯកសារសម្រាប់ចុះបញ្ជី

### ប្រការ ១៩.-

នៅក្នុងរយៈពេលមិនលើសពី៣០(សាមសិប)ថ្ងៃ ក្រោយពេលមហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្មត្រូវបានបញ្ចប់ គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មត្រូវសម្របសម្រួលជាមួយក្រុមប្រឹក្សាភិបាលជាប់ឆ្នោត ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសហភាពសហគមន៍កសិកម្មនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដើម្បីទទួលបាននូវនីត្យានុកូលភាពរបស់សហភាពសហគមន៍កសិកម្ម។

ពាក្យស្នើសុំចុះបញ្ជីសហភាពសហគមន៍កសិកម្មត្រូវមានការបញ្ជាក់ត្រឹមត្រូវពី មេឃុំ ឬចៅសង្កាត់ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមីដែលសហភាពសហគមន៍កសិកម្មនោះតាំងនៅ។

### ប្រការ ២០.-

ការស្នើសុំចុះបញ្ជីសហភាពសហគមន៍កសិកម្ម ត្រូវភ្ជាប់ឯកសារចាំបាច់ដូចខាងក្រោម៖

១- ពាក្យសុំចុះបញ្ជីទទួលស្គាល់សហភាពសហគមន៍កសិកម្ម ដោយមានការបញ្ជាក់ពីអាជ្ញាធរ និងអង្គភាពពាក់ព័ន្ធ។

២- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសហគមន៍កសិកម្មនីមួយៗ ឬវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់នីតិបុគ្គលឯកជនដែលស្នើសុំបង្កើតជាសហភាពសហគមន៍កសិកម្ម។

៣- របាយការណ៍មហាសន្និបាតកំណើតដំបូងរបស់សហភាពសហគមន៍កសិកម្ម។

៤- ផែនការមុខជំនួញរបស់សហភាពសហគមន៍កសិកម្មដែលត្រូវបង្កើត។

៥- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហភាពសហគមន៍កសិកម្ម។

៦- បញ្ជីសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យរបស់សហភាពសហគមន៍កសិកម្មដោយបញ្ជាក់ពីឈ្មោះ មុខរបរ និងអាសយដ្ឋាន។

៧- ឈ្មោះ ស្លាកសញ្ញា អាសយដ្ឋាន និងរចនាសម្ព័ន្ធរបស់សហភាពសហគមន៍កសិកម្ម ព្រមទាំងបញ្ជីឈ្មោះសមាជិក ដើមទុនរបស់សហភាពហគមន៍កសិកម្ម និងចំនួនភាគហ៊ុនដែលត្រូវកត់ត្រាបញ្ចូលនៅក្នុងលក្ខន្តិកៈរបស់សហភាពសហគមន៍កសិកម្ម។

៨- គំរូហត្ថលេខាឬស្នាមមេដៃស្តាំរបស់ប្រធាន ឬតំណាងរបស់សហភាពសហគមន៍កសិកម្ម។

### ប្រការ ២១.-

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវទទួលពាក្យស្នើសុំចុះបញ្ជីសហភាពសហគមន៍កសិកម្ម ដោយត្រូវចេញបង្កាន់ដៃទទួលពាក្យដែលមានការបញ្ជាក់កាលបរិច្ឆេទទទួលពាក្យស្នើសុំច្បាស់លាស់។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសហភាពសហគមន៍កសិកម្ម នៅក្នុងរយៈពេលមិនលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការដោយគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំ ត្រឹមត្រូវនិងគ្រប់គ្រាន់ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីសហគមន៍កសិកម្ម។

គំរូពាក្យស្នើសុំនិងគំរូវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីសហភាពសហគមន៍កសិកម្មត្រូវកំណត់ នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២២.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម អាចបដិសេធសំណើសុំចុះបញ្ជីសហភាពសហគមន៍ កសិកម្មបាន ក្នុងករណីលទ្ធផលពិនិត្យសំណុំឯកសារពាក្យស្នើសុំចុះបញ្ជីមានភាពមិនសមស្រប ឬផ្ទុយ ទៅនឹងបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីសហគមន៍កសិកម្ម។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវជូនដំណឹងចំពោះគណៈកម្មការរៀបចំបង្កើត សហភាពសហគមន៍កសិកម្ម ដើម្បីធ្វើការកែសម្រួលឡើងវិញនូវសំណុំឯកសារពាក្យស្នើសុំចុះបញ្ជី នៅក្នុងរយៈពេលមិនលើសពី៦០(ហុកសិប)ថ្ងៃដោយគិតចាប់ពីកាលបរិច្ឆេទទទួលសេចក្តីជូនដំណឹង របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។

ក្នុងករណីគណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្មមិនបានធ្វើការកែសម្រួល ឡើងវិញនៅក្នុងរយៈពេលកំណត់ក្នុងសេចក្តីជូនដំណឹង នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម មានសិទ្ធិប្រកាសបដិសេធជាផ្លូវការលើពាក្យស្នើសុំចុះបញ្ជីសហភាពសហគមន៍កសិកម្មនោះ ដោយ បញ្ជាក់ពីមូលហេតុច្បាស់លាស់។

**ប្រការ ២៣.-**

គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម មានសិទ្ធិតវ៉ាចំពោះសេចក្តីសម្រេច របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដែលបដិសេធសំណើសុំចុះបញ្ជីសហភាពសហគមន៍ កសិកម្មរបស់ខ្លួន ដោយត្រូវធ្វើលិខិតតវ៉ាជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងរយៈ ពេលមិនលើសពី៦០(ហុកសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃជូនដំណឹងបដិសេធរបស់នាយកដ្ឋានអភិវឌ្ឍន៍ សហគមន៍កសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចាត់តាំងយន្តការដើម្បីពិនិត្យ ស្រាវជ្រាវ និង វាយតម្លៃឡើងវិញលើសំណើសុំចុះបញ្ជីសហភាពសហគមន៍កសិកម្មដែលធ្វើការតវ៉ា និងត្រូវចេញ សេចក្តីសម្រេចចុងក្រោយលើសំណើនេះ នៅក្នុងរយៈពេលមិនលើសពី៦០(ហុកសិប)ថ្ងៃ ដោយគិត ចាប់ពីថ្ងៃទទួលលិខិតតវ៉ារបស់គណៈកម្មការរៀបចំបង្កើតសហភាពសហគមន៍កសិកម្ម។

**ប្រការ ២៤.-**

នៅពេលដែលសហភាពសហគមន៍កសិកម្ម ត្រូវបានចុះបញ្ជីទទួលស្គាល់ដោយនាយកដ្ឋាន អភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មរួច គណៈកម្មការរៀបចំបង្កើតសហភាព សហគមន៍កសិកម្មត្រូវបញ្ចប់សុពលភាពបំពេញកិច្ចរបស់ខ្លួន និងត្រូវរំលាយដោយស្វ័យប្រវត្តិ។

ក្រុមប្រឹក្សាភិបាលនៃសហភាពសហគមន៍កសិកម្ម ត្រូវចូលបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន ចាប់ពីកាលបរិច្ឆេទដែលសហភាពសហគមន៍កសិកម្មត្រូវបានចុះបញ្ជីជាផ្លូវការ។

សហគមន៍កសិកម្មជាសមាជិក ឬនីតិបុគ្គលឯកជនដែលចូលរួមជាសមាជិកសហភាពសហគមន៍កសិកម្ម ត្រូវបំពេញតួនាទី ភារកិច្ច និងកាតព្វកិច្ច ជាសមាជិករបស់សហភាពសហគមន៍កសិកម្ម ស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហភាពសហគមន៍កសិកម្មខ្លួនព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២៥.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីសហភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីជាផ្លូវការ ដោយត្រូវបិទផ្សាយនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងនៅសាលារាជធានី ខេត្តសាមី ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីសហភាពសហគមន៍កសិកម្មនោះ និងត្រូវចម្លងជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តសាមី០១(មួយ)ច្បាប់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៧.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.........................ខែ...............ឆ្នាំ..... ...ស័ក ព.ស ២៥៦...

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កន្លែងទទួលៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គ្រប់រដ្ឋបាលរាជធានី ខេត្ត
-ដូចប្រការ ២៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ